មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

Cambodian Center for Independent Media


# លិខិតចំហ

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ** : ការធានាឯករាជ្យភាព និង សេរីភាព នៃការផ្សាយតាមទូរទស្សន៍

ដូចចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនសម្តេចមេត្តាជ្រាបថា ថ្វីបើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងប្រទេសយើង កំពុងមានការរីកដុះដាលគួរឱ្យកត់សំគាល់ក៏ដោយ ប៉ុន្តែឯករាជ្យភាពនិងសេរីភាពស្ថាប័នទាំងនេះ ជាពិសេសគឺទូរទស្សន៍ស្ថិតនៅជាចំណុចគួរឱ្យព្រួយបារម្ភខ្លាំងនៅឡើយ ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានទូរទស្សន៍ចំនួន១២ ដែលកំពុងធ្វើការផ្សាយតាមរលកធាតុអាកាស ប៉ុន្តែស្ថាប័នទាំងនោះត្រូវបានគេមើលឃើញថាសុទ្ធតែមិនឯករាជ្យ ដោយស្ថិតក្រោមឥទ្ធិពលនយោបាយ ។ បញ្ហានេះគឺបណ្តាលមកពីការខ្វះយន្តការនិងនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណដោយតម្លាភាព និងសមភាពចំពោះប្រជាពលរដ្ឋខ្មែរទូទៅ ការគ្រប់គ្រងស្ថាប័នទូរទស្សន៍ដោយរដ្ឋាភិបាល និងការស្តីបន្ទោសរបស់មេដឹកនាំនយោបាយជាដើម ។ ជាឧទាហរណ៍ ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានស្តីបន្ទោសដល់ទូរទស្សន៍ CNC និងក្រុមផលិតកម្មវិធីព័ត៌មានរបស់ទូរទស្សន៍នេះ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ កន្លងទៅ ស្តីពីពលករកម្ពុជាចំណាកស្រុកខុសច្បាប់នោះ ត្រូវបានគេគិតថា វាអាចបណ្តាលឱ្យមានការភ័យខ្លាចក្នុងចំណោមអ្នកសារព័ត៌មាន ។

អាស្រ័យហេតុនេះ ខ្ញុំបាទសូមឆ្លៀតយកឱកាសនៃការប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក ដែលនឹងប្រព្រឹត្តនៅថ្ងៃទី០៣ ខែឧសភា ខាងមុខនេះ ស្នើសុំសម្តេចនាយករដ្ឋមន្ត្រី ចាត់គ្រប់វិធានការដើម្បីធានាឯករាជ្យ និងសេរីភាពនៃការផ្សាយកម្មវិធីនានារបស់ស្ថាប័នទូរទស្សន៍ និងបញ្ចប់រាល់ការបំភិតបំភ័យដល់ក្រុមអ្នកផលិតកម្មវិធី ។

សូមសម្តេច មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ភ្នំពេញ, ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៣

**នាយកប្រតិបត្តិ**

**ប៉ា ង្វនទៀង**